# Public Comment 101



**សហគមន៍ The Duwamish Valley ត្រូវបានគេសួរជារឿយៗ ឱ្យមានការស្នើសុំផ្តល់មតិយោបល់ជាសាធារណៈ។ យើងបានបង្កើតគោលការណែនាំដ៏ងាយស្រួលមួយដើម្បីគាំទ្រសំណើរនេះ!**

## តើការផ្តល់មតិយោបល់ជាសាធារណៈគឺជាអ្វី?

ការផ្តល់មតិយោបល់ជាសាធារណៈ គឺជាសេចក្តីថ្លែ ការណ៍ផ្តល់តាមរយះជាលាយលក្ខណ៍អក្សរ តាមរយះការនិយាយស្តី ឬតាមរយះសេចក្តីថ្លែ ការណ៍ថតជាសម្លេងដែលត្រូវបានផ្តល់ដោ សាធារណៈជនទូទៅ ហើយប្រគល់ឱ្យទៅទីភ្នាក់ងារមួយក្នុងអំឡុងពេលដែលកំណត់ដោយច្បាប់។
គេចង់ធ្វើឱ្យដំណើរការរបស់រដ្ឋាភិបាលកាន់តែមា តម្លាភាពដល់ប្រជាជន ដែលការសម្រេចចិត្តទាំងនេះនឹងអាចប៉ះពាល់ដល់ពួកគេ។

## តើហេតុអ្វីបានជាអ្នកគួរបញ្ចេញមតិយោបល់?

ការបញ្ចេញមតិយោបល់គឺជាវិធីដ៏សំខាន់បំផុតមួយដើម្បីធ្វើឱ្យសំឡេងរបស់អ្នកមានឥទ្ធិពលដល់ការសម្រេចចិត្ត។ មតិយោបល់របស់សាធារណៈអាចធ្វើឱ្យការសម្រេចចិត្តផ្នែកបរិស្ថានមានភាពរឹងមាំ ដោយផ្តល់ទស្សនដល់ទីភ្នាក់ងារនូវការពិត ឬទស្សនៈដែលមានការខ្វះខាត។

**1** **តើអ្នកជានរណា? ជួយបែងចែកមតិយោបល់របស់អ្នកពីអ្នកដ៏ទៃ។**

**2** **តើហេតុអ្វីបានជាប្រធានបទនេះសំខាន សម្រាប់អ្នក? តើវានឹងប៉ះពាល ដល់សហគមន៍របស់អ្នកយ៉ាងដូចម្តេចដែរ?**

**ខ្ញុំឈ្មោះ Jane Smith ។ ខ្ញុំជាអ្នករស់នៅ South Park ។**
**ផែនការសម្រាប់សាធារណៈចូលរួមក្នុងសួន Duwamish Waterway Park មានសារៈសំខាន់ចំពោះខ្ញុំ ពីព្រោះខ្ញុំរស់នៅ 4 ប្លុកពីសួននេះ ហើយខ្ញុំចង់ឱ្យគ្រួសាររបស់ខ្ញុំមានសុវត្ថិភាព**
**និងមានសុខភាពល្អនៅពេលទៅលេងកម្សាន្តនៅទីនោះ។ South Park គឺជាសហគមន៍យុត្តិធម៌បរិស្ថាន ហើយយើងត្រូវប្រឈមនឹងបញ្ហាជាច្រើនដូចជា ទីតាំងដែលមានជាតិកខ្វក់ (Superfund Site) ខ្យលអាកាសមិនល្អ និងគ្មានកន្លែងធំទំលាយនៅក្នុងសួនជាដើម ។ល។ ដែលអាចជះឥទ្ធិពអវិជ្ជមានដល់សុខភាពរបស់យើង។ ខ្ញុំមានការព្រួយបារម្ភថា វាមិនល្អសម្រាប់សុខភាពក្នុងការដើរលេងកម្សាន្ត ឬលេងកន្សាន្តនៅតាមឆ្នេរស្ទឹងក្នុងសួន Duwamish Waterway Park ពីព្រោះនៅទីនោះមានសារធាតុកខ្វក់មួយចំនួនដែលលើសពីស្តង់ដារសម្អាត ហើយត្រូវការការធ្វើតេស្តបន្ថែមទៀត។**
**សូមអរគុណចំពោះការដាក់ផ្លាកសញ្ញាប្រាប់យើងពីរបៀបថែរក្សាសុវត្ថិភាពនៅក្នុងសួន Duwamish Waterway Park ។ ប៉ុន្តែវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ខ្ញុំគិតថា គេគួរតែដំឡើងកន្លែងសម្រាប់លាងសម្អាតដូចនៅឆ្នេរ Alki Beach ។ នេះគឺជាការសំខាន់មួយ ពីព្រោះនៅកន្លែងអាគារដែលខ្ញុំរស់នៅ មិនមានបំពងទឹកនៅខាងក្រៅដែលអាចប្រើប្រាស់បានស្រួលសម្រាប់លាងជើងឬលាងក្រញ៉ាំជើងឆ្កែរបស់យើងទេ។**

**3** **តើចំណុចណាខ្លះដែលអ្នកគាំទ្រ? តើចំណុចអ្វីដែលអ្នកមិនគាំទ្រ?**

**4** **តើដំណោះស្រាយអ្វីផ្សេងទៀតដែលអ្នកអាចយកមកជំនួសបាន?**

JustHealthAction

អត្ថបទនេះត្រូវបានផ្តល់ជំនួយមូនិធិដោយកម្មវិធីផ្តល់មូនិធិសម្រាប់អោយសាធារណៈជនចូលរួម Public Participation Grant ដែលចេញពីក្រសួងបរិស្ថានវិទ្យានៃរដ្ឋវ៉ាស៊ីងតោន ។
ខ្លឹមសារក្នុងអត្ថបទនេះត្រូវបានពិនិត្យមើលឡើងវិញដើម្បីអោយមានភាពស៊ីសង្វាក់គ្នាសម្រាបការទទួលជំនួយមូនិ ធិ ប៉ុន្តែមិនចាំបាច់ត្រូវបានទទួលស្គាល់ដោយទីភ្នាក់ងារទេ។
ចំពោះព័ត៌មានបន្ថែមសូមទាក់ទង jamie@drcc.org ឬចូលទៅកាន់ drcc.org

DUWAMISH RIVER COMMUNITY COALITION